# ជំពូក ២៥

*ខាងចនា លោកអ័ប្រាហាំយកប្រពន្ធមួយទៀតឈ្មោះ កិទូរ៉ា មរណៈភាព របស់អ័ប្រាហាំ អេសាវ និង យ៉ាកុប*

ជំពូក២៥ សម្តែងពីមរណៈភាពរបស់លោកអ័ប្រាហាំ។ អ៊ីសាក និង រេបិកា បង្កើតបានកូនភ្លោះឈ្មោះ អេសាវ និង យ៉ាកុប។ មិនតែប៉ុណ្ណោះ ជំពូកនេះរៀបរាប់ពីពូជពង្សរបស់អ៊ីសម៉ាអែល និងពូជពង្សរបស់អ៊ីសាក។ រឿងទាក់ទងជាមួយនឹងសិទ្ធិកូនច្បងមាននិយាយនៅក្នុងជំពូកនេះដែរ។ មិនតែប៉ុណ្ណោះសោត ជំពូកនេះបរិយាយពីជីវិតចុងក្រោយបង្អស់របស់លោកអ័ប្រាហាំ ប៉ុន្តែ តាមពិតទៅរឿងរបស់លោកចប់តាំងពីជំពូក២៣ត្រង់ពេលដែលលោកចាត់បាវបម្រើអោយទៅដណ្តឹងភរិយាអោយអ៊ីសាកមកម្ល៉េះ។

## អ័ប្រាហាំយកប្រពន្ធមួយទៀតឈ្មោះ កិទូរ៉ា

**អ័ប្រាហាំគាត់ក៏យកប្រពន្ធ១ទៀត ឈ្មោះកិទូរ៉ា នាងនោះបង្កើតកូនឱ្យគាត់ គឺស៊ីមរ៉ាន យ៉ុកសាន មីដាន ម៉ាឌាន អ៊ីសបាក់ នឹងស៊ូអា (លោកុ. ២៥:១-២)។**

គ្រួសារលោកអ័ប្រាហាំធំណាស់ ពិសេសបន្ទាប់ពីសារ៉ាជាភរិយាមុនរបស់លោកទទួលមរណៈភាពទៅ។ មានអ្នកខ្លះបាននិយាយថា "ក្រោយដែលអីសាកប្រសូតមកលោកអ័ប្រាហាំលែងមានកូនទៀតហើយ"។ តាមពិតទៅយ៉ាងដូច្នោះមែន ប៉ុន្តែបើព្រះធ្វើការអ្វីមួយហើយ ព្រះអង្គនឹងសម្រេចការនោះអោយកើតជាពិត។ នៅក្នុងសាច់រឿងយើងឃើញថា លោកអ័ប្រាហាំមិនមែនគ្រាន់តែបង្កើតបានអីសាកមួយប៉ុណ្ណោះទេ លោកថែមទាំងបានបង្កើតកូនជាច្រើនទៀត ដែលបណ្តាលអោយគ្រួសាររបស់លោករីកសាយយ៉ាងធំក្រៃលែង។

ក្នុងចំណោមកូនលោកទាំងប៉ុន្មាននោះ មានពីរនាក់ដែលយើងគួរកត់សម្គាល់ គឺមីដានហើយនិងម៉ាឌាន។ កូនរបស់លោកផ្សេងៗឯទៀតនោះ សុទ្ធតែនាំគ្នាសាយគ្រាយពូជរហូតដល់ទៅកើតជានគរបាន ប៉ុន្តែ ខ្ញុំមិនអាចស្គាល់នគររបស់គេទាំងអស់បានទេ។ ខ្ញុំយកចិត្តទុកដាក់ជាមួយនឹងសាសន៍ ម៉ាឌានតែមួយ ពីព្រោះមានរឿងរបស់គាត់ទាក់ទងជាមួយនឹងរឿងក្នុងព្រះគម្ពីរទាំងមូល។

ពេលក្រោយយូរលង់មកទៀត ម៉ូសេបានភៀសខ្លួនទៅនៅទឹកដីនៃសាសន៍ម៉ាឌាន ហើយក៏បានយកប្រពន្ធនៅស្រុកនោះ។ សាសន៍ម៉ាឌាន គឺជាកូនរបស់អ័ប្រាហាំ ឯសាសន៍មីដាន ក៏ជាកូនអ័ប្រាហាំដូចគ្នាដែរ។ ត្រង់នេះយើងឃើញថា លោកអ័ប្រាហាំមានកូនជាច្រើនផ្សេងទៀត ប៉ុន្តែព្រះជាម្ចាស់សម្រេចរើសយកពូជអ័ប្រាហាំតាមរយៈអីសាកយកមកប្រើប្រាស់ ហើយកូនដ៏ទៃទៀតនោះ ព្រះអង្គមិនបានយកមកប្រើដើម្បីអោយព្រះអង្គសង្គ្រោះបានប្រសូតមកនោះទេ។ ព្រះអង្គមិនរើសពូជរបស់អីសម៉ាអែល

ឬក៏ពូជមីដាន ឬក៏ពូជម៉ាឌានឡើយ។ ពួកជនទាំងនោះ ជាជនពនេចររស់នៅក្នុងទីរហោស្ថាន។

## មរណៈភាពរបស់លោកអ័ប្រាហាំ

**អ័ប្រាហាំគាត់ប្រគល់របស់ទ្រព្យទាំងអស់ ឱ្យដល់អ៊ីសាក តែបានចែកអំណោយខ្លះដល់ពួកកូនចៅរបស់ប្រពន្ធចុងគាត់ដែរ រួចក៏ឱ្យគេចាកចេញពីអ៊ីសាកកូនគាត់ ទៅឯស្រុកខាងកើតវិញ ក្នុងកាលដែលគាត់នៅរស់នៅឡើយ រីឯចំនួនឆ្នាំអាយុរបស់អ័ប្រាហាំ ដែលគាត់រស់នៅរួមទាំងអស់បាន១៧៥ឆ្នាំ កាលគាត់បានអាយុវែងល្អ ព្រមទាំងស្កប់ស្កល់នឹងអាយុរបស់ខ្លួនហើយនោះក៏ផុតដង្ហើមស្លាប់ទៅ បានប្រមូលទៅមូលនឹងញាតិគាត់វិញ រួចអ៊ីសាកនឹងអ៊ីសម៉ាអែលជាកូន ក៏បញ្ចុះសពគាត់នៅក្នុងរអាងម៉ាក់ពេឡា នាចំការអេប្រុនកូនសូហារ ជាសាសន៍ ហេត ដែលនៅខាងមុខ ម៉ាមរេ ជាចំការដែលអ័ប្រាហាំបានទិញពីពួកកូនចៅហេតមក គឺនៅទីនោះហើយដែលបានបញ្ចុះសពអ័ប្រាហាំនឹងសារ៉ាជាប្រពន្ធ (លោកុ.២៥:៥-១០)។**

អ៊ីសម៉ាអែលបានមកបញ្ចុះសពលោកអ័ប្រាហាំដែរ ដ្បិតលោកត្រូវជាឪពុករបស់ខ្លួន។ ដូច្នេះ អ៊ីសាក ហើយនិងអ៊ីសម៉ាអែលទាំងពីរនាក់រួមគ្នាបញ្ចុះសពឪពុក។ ក្រោយពីបានធ្វើបុណ្យសពឪពុករួចហើយ អ៊ីសាកបានវិលទឹកន្លែងមកនៅឯភូមិដែលលោកជួបជាមួយនឹងរេបិកាជាលើកដំបូង។

**ក្រោយដែលអ័ប្រាហាំស្លាប់ទៅ នោះព្រះទ្រង់ប្រទានពរឱ្យអ៊ីសាកជាកូនគាត់ អ៊ីសាកក៏នៅត្រង់អណ្តូងឡាហាយ-រយ (លោកុ.២៥:១១)។**

ចាប់ពីខ១២-១៨ យើងឃើញមានរាប់តំណវង្សរបស់អ៊ីសម៉ាអែលដែលត្រូវជាកូនរបស់លោកអ័ប្រាហាំជាមួយនឹងនាងហាការ ជាឈ្នួលរបស់សារ៉ា។ បញ្ជីពង្សាវតានេះ ឃើញរៀបរាប់ជាមុនដំបូង។ ខ្ញុំសូមរំឭកលោកអ្នកបងប្អូនម្តងទៀតថា ព្រះវិញ្ញាណបរិសុទ្ធព្រះអង្គប្រើវិធីនេះនៅក្នុងគម្ពីរលោកុប្បត្តិ។ ពង្សាវតាដែលមិនបង្កើតព្រះយេស៊ូវគ្រីស្ទនោះ ត្រូវបំបាត់បន្តិចម្តងៗពីក្នុងបទគម្ពីរ។ ប៉ុន្តែ ឯពង្សាវតាណាដែលព្រះគ្រីស្ទប្រសូតមកនោះ ត្រូវរៀបរាប់ជាបន្តទៅទៀត។ ដូច្នេះ យើងឃើញពង្សាវតារបស់អ៊ីសម៉ាអែលរៀបរាប់មុនគេបង្អស់រួចហើយបាត់ទៅ។ បន្ទាប់មកយើងយកពង្សាវតាររបស់អ៊ីសាកមករៀបរាប់បន្តទៅទៀត។

**ហើយនេះជាដំណវង្ស ពីអ៊ីសាក ជាកូនអ័ប្រាហាំ គឺអ័ប្រាហាំបាន បង្កើតអ៊ីសាក (លោកុ. ២៥:១៩)។**

ខគម្ពីរនេះទាក់ទងជាមួយនឹងខគម្ពីរម៉ាថាយ១:២ដែលថែងថា "អ័ប្រាហាំបង្កើតអ៊ីសាកៗបង្កើតយ៉ាកុប..."។ លោកអ័ប្រាហាំមានកូនប្រុសជាច្រើន ហើយកូនប្រុសរបស់លោកនីមួយៗសុទ្ធតែបានបង្កើតកូនបានច្រើនសន្ធឹកសន្ធាប់តទៅទៀត។ ប៉ុន្តែព្រះអង្គជ្រើសរើសយកតែពូជរបស់អ៊ីសាកមកនិយាយតែប៉ុណ្ណោះ។ សូមយើងបំភ្លេចគ្រួសាររបស់អ៊ីសម៉ាអែល របស់មីដាន និងរបស់ម៉ាឌានចុះ។ គ្រួសាររបស់លោកទាំងនោះ មានទាក់ទងជាមួយនឹងគ្រួសាររបស់លោកអ៊ីសាកខ្លះៗដែរ ប៉ុន្តែយើងមិនតាមដានខ្សែស្រឡាយរបស់លោកទាំងនោះទេ។

**ឯអ៊ីសាក កាលយករេបិកាជាកូនបេធូអែលសាសន៍អើរ៉ាម ជាអ្នកនៅស្រុកប៉ាដាន់-អើរ៉ាម ដែលនាងជាប្អូនឡាបាន់មកធ្វើជាប្រពន្ធ នោះគាត់មានអាយុ៤០ឆ្នាំ ហើយអ៊ីសាកគាត់សូមអង្វរដល់ព្រះយេហូវ៉ាពីដំណើរប្រពន្ធគាត់ ពីព្រោះនាងជាស្ត្រីអារ ហើយព្រះយេហូវ៉ាទ្រង់ទទួលព្រមតាម រួចនាងក៏មានទំងន់ (លោកុ.២៥:២០-២១)។**

ដំបូងឡើយ នាងរេបិកាក៏ជាស្ត្រីអារដែរ។ ប៉ុន្តែអ៊ីសាកបានធ្វើកិច្ចសន្យាជាមួយព្រះជាម្ចាស់ បានជាព្រះអង្គអនុញ្ញាតអោយនាងមានទម្ងន់កើតបានជាកូនភ្លោះ។

**ឯកូនក្នុងផ្ទៃនាងវាប្រធាក់គ្នា នាងក៏និយាយថា បើដូច្នេះ តើនឹងកើតមានជាដូចម្តេចទៅ រួចនាងទៅទូលសួរដល់ព្រះយេហូវ៉ា (លោកុ.២៥:២២)។**

ការណ៍ដែលកូនទាំងពីរនេះប្រធាក់គ្នាក្នុងពោះ សម្តែងអំពីស្ថានភាពសព្វថ្ងៃនេះ ដែលពូជពង្សលោកទាំងពីរចេះតែប្រធាក់គ្នានៅលើលោកយើងជាប្រចាំ។ ដរាបណានៅមានពូជទាំងពីរនេះ ដរាបនោះមានការប្រធាក់គ្នារវាងពន្លឺនិងងងឹត រវាងសេចក្តីល្អនិងសេចក្តីអាក្រក់ រវាងព្រះវិញ្ញាណនិងសាច់ឈាមជានិច្ចជាកាល។ ធម្មតាកូនរបស់ព្រះជាម្ចាស់រមែងស្គាល់រឿងនេះច្បាស់លាស់ណាស់។ ហេតុនេះហើយបានជាសាវ័កប៉ូល លោកយកមកបញ្ជាក់ម្តងទៀតនៅក្នុងគម្ពីររ៉ូមជំពូក៧។ ចំណែកនាងរេបិកាមិនយល់អំពីហេតុការណ៍នេះទេ បានជានាងទូលសួរដល់ព្រះជាម្ចាស់ថា "តើនឹងកើតមានជាដូចម្តេចទៅ?"

**ព្រះយេហូវ៉ាទ្រង់មានបន្ទូលប្រាប់នាងថា មាននគរ២នៅក្នុងផ្ទៃឯង គឺនឹងមានសាសន៍២ចេញពីពោះឯងមក សាសន៍១នឹងបានខ្លាំងជាងសាសន៍១ គឺកូនច្បងនឹងត្រូវបំរើប្អូន (លោកុ.២៥:២៣)។**

ព្រះជាម្ចាស់មានបន្ទូលថា កូនច្បងនឹងត្រូវបម្រើប្អូន។ រេបិកា គួរតែជឿពាក្យដែលព្រះជាម្ចាស់មានបន្ទូលនេះ។

> **លុះនាងគ្រប់ខែហើយ នោះមើល មានកូនភ្លោះតាំងនៅក្នុងផ្ទៃនាង កូនដែលកើតមកមុន នោះមានសម្បុរក្រហមទង់ដែងនៅពេញខ្លួន ៗស័យដូចជាអាវរោម គេបានឱ្យឈ្មោះថាអេសាវ (លោកុ២៥:២៤-២៥)។**

ឈ្មោះអេសាវមានន័យថា "ក្រហម" ឬ "ពណ៌ដី"។ អេសាវកើតមុនបានជាគេហៅគាត់ថា ជាកូនច្បង ប៉ុន្តែកូនច្បងត្រូវបម្រើប្អូន។

> **បន្ទាប់នោះ កូនប្អូនក៏ចេញមក ទាំងមានដៃកាន់កែងជើងអេសាវ នោះគេឱ្យឈ្មោះថា យ៉ាកុប ឯអ៊ីសាកគាត់មានអាយុ៦០ឆ្នាំ ហើយ ក្នុងកាលដែលនាងបង្កើតកូនមក (លោកុ.២៥:២៦)។**

អ៊ីសាករៀបការជាមួយនឹងរេបិកា២០ឆ្នាំទើបបានកូនភ្លោះទាំងពីរនោះមក។ អេសាវកើតមុន បានជាអ្នកទាំងពីរដាក់ឈ្មោះដាក់ឈ្មោះកូននោះថា "ក្រហម"។ ឯយ៉ាកុបវិញ កើតមកកាន់កែងជើងបងជាប់ ដូច្នេះបានជាអ្នកទាំងពីរដាក់ឈ្មោះកូននោះ

ថា "យ៉ាកុប" ព្រោះមានន័យថា អ្នកដែងចង់មកមុន។ ទោះបីជាលោកយ៉ាកុបកើតមក ក្រោយយ៉ាងណាក៏ដោយ ក៏សេចក្តីសន្យារបស់ព្រះត្រូវមកលើរូបលោកទៅវិញ។

**កូនទាំង២នោះក៏ធំឡើង អេសាវបានទៅជាអ្នកចំណានខាងឯ វិជ្ជាព្រានប្រមាញ់ ជាមនុស្សនៅតែទីវាល ឯយ៉ាកុបជាមនុស្ស រមទម នៅតែក្នុងត្រសាលវិញ (លោកុ.២៥:២៧)។**

ក្មេងទាំងពីរនេះ កើតដឹងក្តីនៅក្នុងផ្ទះតែមួយ។ ក្មេងទាំងពីរនេះមិនមែនគ្រាន់តែប្រធាក់គ្នា ពេលដែលនៅក្នុងផ្ទៃម្តាយប៉ុណ្ណោះទេ ប៉ុន្តែគេចាប់ផ្តើមដែងគ្នាក្នុងពេលដែលគេធំដឹងក្តី ហើយថែមទៀតផង។ ក្មេងទាំងពីរនេះ មានការយល់ដឹងខុសគ្នា មានទស្សនៈប្រចាំជីវិតខុសគ្នា គិតគូរខុសគ្នា អត្តចរិកក៏ខុសគ្នាស្រឡះដែរ។ កាលដំបូងឡើយខ្ញុំឃើញថា អេសាវមានលក្ខណៈសុភាពជាងយ៉ាកុប។ ប៉ុន្តែយើងមិនគួរវិនិច្ឆ័យអត្តចរិករបស់មនុស្សតាមលក្ខណៈរូបសម្បត្តិខាងក្រៅនោះទេ។ យើងត្រូវវិនិច្ឆ័យអត្តចរិករបស់មនុស្សតាមចិត្តរបស់គេខាងក្នុងវិញទើបត្រឹមត្រូវ។

"កូនទាំងពីរនោះ ក៏ធំឡើង"។ អេសាវជាព្រានប្រមាញ់ ជាអ្នកដែលចូលចិត្តដើរតាមវាល ហើយជាអ្នកចូលចិត្តប្រើកម្លាំងបាយ។ សព្វថ្ងៃនេះ មានមនុស្សច្រើនណាស់ ដែលមានលក្ខណៈដូចជាលោកអេសាវដូច្នេះដែរ។ មនុស្សប្រភេទអេសាវ បានហាត់ពត់ខ្លួនប្រាណជាមួយនឹងកីឡា ឬមួយក៏ដោយប្រើសកម្មភាពផ្សេងៗដ៏ទៃទៀតដែល

ប្រើកម្លាំងបាយ។ ជនទាំងនោះ មិនសូវយល់ពីសេចក្តីខាងឯព្រលឹងវិញ្ញាណប៉ុន្មានទេ។ លោកអេសាវចូលចិត្តតែប្រើកម្លាំងបាយ ហើយកម្លាំងបាយនេះ ជានិមិត្តរូបនៃសាច់ឈាម។

ចំណែកឯយ៉ាកុបវិញជាមនុស្សរមទម្យ ហើយនៅតែក្នុងត្រសាលប៉ុណ្ណោះ។ យ៉ាកុប ជាមនុស្សដែលគាប់ចិត្តម្តាយ ពោលគឺគាត់ធ្វើអ្វីទាំងអស់ ដែលម្តាយគាត់ប្រាប់អោយធ្វើ។ ដូច្នេះយ៉ាកុបមានលក្ខណៈដូចម្តាយ ចំណែកឯអេសាវវិញ មានលក្ខណៈដូចឪពុក។

> **អ៊ីសាកក៏ស្រឡាញ់ពេញចិត្តចំពោះអេសាវ ដោយព្រោះធ្លាប់បានបរិភោគសាច់ក្តាន់របស់គាត់ ឯរេបិកានាងស្រឡាញ់យ៉ាកុបវិញ (លោកុ.២៥:២៨)។**

ខាងលើនេះ ជាឧប្បទ្ទវហេតុដែលបណ្តាលអោយកើតជាវិបត្តិឡើងនៅក្នុងផ្ទះនីមួយៗ។ កាលណាមានឪពុកកាន់ជើងកូនមួយ ហើយម្តាយកាន់ជើងកូនមួយទៀត បញ្ហាតែងតែកើតឡើងក្នុងផ្ទះជានិច្ចជាកាល។ ភស្តុតាងនៅក្នុងព្រះគម្ពីរនេះ ជាឧទាហរណ៍ស្រាប់។

អ៊ីសាកស្រឡាញ់អេសាវជាកូនរបស់លោក ពីព្រោះលោកតែងតែបរិភោគសាច់ក្តាន់ដែលកូននោះទៅបាញ់បាន។ ពេលដែលអេសាវទៅបរបាញ់តែងតែនាំយកមកផ្ទះវិញ នូវសត្វអ្វីមួយជាមិនខាន។ លោកអ៊ីសាកចូលចិត្តកូនលោកណាស់ ពីព្រោះជា

មនុស្សដែលមានមាឌមាំ សាច់ដុំម៉ាន់ ព្រមទាំងឧហ្សាហ៍ដើរព្រៃណាស់។ ប៉ុន្តែ រេបិកាវិញ ស្រឡាញ់យ៉ាកុប ពីព្រោះជាក្មេងដែលចូលចិត្តនៅផ្ទះ។

ខ្ញុំបានជំរាបលោកអ្នកម្តងរួចមកហើយថា អេសាវមានរូបរាងសង្ហារជាង យ៉ាកុប។ តាមការសង្កេតមើលរូបរាងខាងក្រៅ អេសាវហាក់ដូចជាមនុស្សដែលយល់ដឹងច្រើនណាស់។ កិរិយារបស់គាត់ សម្តែងរៀងរាល់ថ្ងៃដែរថា គាត់ជាមនុស្សឆ្លាតវាងវៃ។ គាត់មិនសូវជាអល់ឯកនឹងធ្វើអំពើអាក្រក់ប៉ុន្មានទេ ថ្វីដ្បិតព្រះជាម្ចាស់បានបង្ហាត់បង្រៀនបុរសរូបនេះ ជារឿយៗយ៉ាងណាក៏ដោយចុះ។ ការសំខាន់ដែលយើងឃើញត្រង់នេះគឺថា ថ្វីដ្បិតលោកអេសាវមើលទៅហាក់ដូចជាមនុស្សដែលពេញលក្ខណៈ ប៉ុន្តែនៅក្នុងចិត្តរបស់គាត់គ្មានកន្លែងណាសម្រាប់ព្រះទេ។ គាត់ជាមនុស្សរបស់លោកីយ៍សុទ្ធសាធ ពោលគ្រាន់តែជាមនុស្សដែល រស់គ្រាន់តែមានរូបតែប៉ុណ្ណោះ។

ចំណែកឯយ៉ាកុបវិញ មានចំណងចិត្តជាមួយនឹងកិច្ចការខាងព្រលឹងវិញ្ញាណជានិច្ច។ ថ្វីដ្បិតព្រះជាម្ចាស់ប្រើពេលវេលាច្រើនណាស់ ដើម្បីដុសខាត់មនុស្សរូបនេះ អោយក្លាយត្រឡប់ទៅជាមនុស្ស ដែលព្រះអង្គសព្វព្រះហឫទ័យ គាត់ជាមនុស្សដែលចូលចិត្តធ្វើការតាមបំណងព្រះជាម្ចាស់។ ដំណើររឿងរបស់យ៉ាកុបវែង ហើយចម្ងល់ទាំងអម្បាលមាណនៃព្រះគម្ពីរលោកុប្បត្តិ ស្ទើរសុទ្ធសឹងតែជារឿងរបស់លោក។ លោកជាមនុស្សដែលដើរតាមព្រះ តែយើងមិនទាន់ឃើញភស្តុតាងបែបនេះ ទាល់តែដល់ដំណាក់កាលចុងក្រោយបង្អស់ នៃជីវិតរបស់លោក។

ខ្ញុំជំរាបរួចមកហើយថា មានហេតុការណ៍មិនល្អកើតឡើងនៅក្នុងផ្ទះនេះ។

ឯមូលហេតុនោះ គឺដូចលោកអ្នកបងប្អូនជ្រាបរួចមកហើយថា កាលណាមានឪពុកកាន់ជើងកូនមួយហើយម្ដាយកាន់ជើងកូនមួយទៀត ផ្ទះសម្បែងណា ក៏ដូចជាផ្ទះណាដែរ តែងតែមានវិបត្តិជានិច្ចជាកាល ហើយខ្ញុំមិនហៅផ្ទះនោះថា ជាផ្ទះដែលមានសុភមង្គលទេ។

> **សម័យ១យ៉ាកុបកំពុងតែស្ងសំឡ នោះអេសាវមកពីវាលទាំងហេវ ក៏និយាយថា សូមចែកសំឡក្រហមនោះ ឱ្យបងបរិភោគផង ដ្បិតបងហេវណាស់ ហេតុនោះបានជាគេហៅឈ្មោះគាត់ថា អេដំម វិញតែយ៉ាកុបនិយាយថា សូមឱ្យបងផ្ទេរអំណាចមរដករបស់បងច្បងមកឱ្យខ្ញុំសិននោះអេសាវឆ្លើយថា បងស្លាប់ឥឡូវហើយ ដូច្នេះ តើអំណាចនោះមានប្រយោជន៍អ្វីដល់បងទៀត (លោកុ. ២៥:២៩-៣២)។**

សាច់រឿងខាងលើ សម្ដែងអំពីបុគ្គលិកលក្ខណៈផ្សេងគ្នា របស់កូនប្រុសទាំងពីររូបនេះ។ អេសាវបានត្រឡប់មកពីវាលវិញ ហើយគាត់អស់កម្លាំងណាស់។ បើតាមពិតទៅអេសាវមិនមែនឃ្លានរហូតដល់ស្លាប់នោះទេ ពីព្រោះមនុស្សទាំងឡាយណាដែលរស់នៅក្នុងផ្ទះរបស់អ័ប្រាហាំមិនដែលស្លាប់ដោយអត់បាយឡើយ។ ប៉ុន្តែក្នុងពេលដែលអេសាវកំពុងហត់នឿយ គាត់ត្រឡប់មកផ្ទះវិញ គ្មានម្ហូបណាដែលរៀបចំហើយជាស្រេចផ្សេងទៀតក្រៅពីតែសំឡដែលយ៉ាកុបបានស្ងហើយនោះ។ យ៉ាកុបជាមនុស្សដែល

នៅផ្ទះ ដូច្នេះគាត់ចេះដាំស្លយ៉ាងស្ទាត់ជំនាញ។

"សូមចែកសំឡក្រហមនោះឱ្យបងបរិភោគផង ដ្បិតបងហេវណាស់ ហេតុនោះបានជាគេហៅគាត់ថា អេដំមវិញ"។ អេដំមប្រែថា ពណ៌ក្រហម ឬមួយពណ៌ដី ហើយអេសាវក៏មានន័យយ៉ាងដូច្នេះដែរ។ បុរសនេះសុំសំឡពីយ៉ាកុប ដើម្បីបរិភោគ ហើយយ៉ាកុបក៏ឃើញថា ជាឱកាសល្អសម្រាប់គាត់ធ្វើការមួយដែរ។ ឥឡូវនេះ យើងឃើញអ្នកលេងល្បិច ទល់នឹងអ្នកលេងកម្លាំង ពោលគឺយ៉ាកុបប្រើល្បិច ដើម្បីអោយបងផ្ទេរអំណាចមរតកកូនច្បង មកអោយខ្លួន។ យ៉ាកុបបាននិយាយថា "សូមអោយបងផ្ទេរអំណាចមរតកបងច្បងមកអោយខ្ញុំសិន"។

សូមយើងពិនិត្យមើលតម្លៃនៃសិទ្ធិជាបងច្បងនៅក្នុងអត្ថបទនេះ។ ម្នាក់ដែលមានសិទ្ធិជាបងច្បងមានន័យថា បុគ្គលនោះជាមេនៃគ្រួសារ។ មិនតែប៉ុណ្ណោះបុគ្គលនោះអាចធ្វើជាសង្ឃរបស់គ្រួសារផងក៏បាន។ ក្នុងករណីគ្រួសារនេះ អេសាវដែលមានសិទ្ធិជាបងច្បងអាចក្លាយទៅជាខ្សែស្រឡាយ ដែលព្រះយេស៊ូវគ្រីស្ទ ទ្រង់ប្រសូតចេញពីខ្សែស្រឡាយនោះផង។ ប៉ុន្តែតើលោកអ្នកបងប្អូនគិតថាលោកអេសាវមានឯកសិទ្ធិសម្រាប់ទទួលខ្សែស្រឡាយនេះឬទេ? យ៉ាកុបដឹងច្បាស់ថា អេសាវមិនមានឯកសិទ្ធិនេះទេ។ អេសាវមិនមានបំណងចំណូលចិត្តអ្វីនឹងធ្វើការណ៍យ៉ាងដូច្នេះសោះ ហើយបើធ្វើជាសង្ឃសម្រាប់គ្រួសារទៅទៀតនោះ គាត់ថា "ខ្ញុំនឹងបួសជាសង្ឃ បើគ្មានផ្លូវណាសម្រាប់ ជ្រើសរើសទេ"។

សព្វថ្ងៃនេះ គ្រីស្ទបរិស័ទច្រើនណាស់ ដែលមានលក្ខណៈដូចគ្នាបេះបិទនឹង

អេសាវ។ ពេលសុំអោយធ្វើការអ្វីមួយ ដើម្បីបម្រើព្រះយេស៊ូវ គេឆ្លើយតបមកវិញដោយងងើលថា "ខ្ញុំមិនមែនគ្រូគង្វាលឯណា ខ្ញុំក៏មិនមែនគ្រូអធិប្បាយដែរ ខ្ញុំមិនអាចធ្វើបានទេ!" មានមនុស្សច្រើនណាស់សព្វថ្ងៃនេះ មិនចូលចិត្តធ្វើការងារអ្វីដែលទាក់ទងខាងព្រលឹងវិញ្ញាណឡើយ។ គេក៏មិនបង្ហាញទឹកចិត្តថា គេចង់ធ្វើកិច្ចការណាដែលទាក់ទងខាងព្រលឹងវិញ្ញាណសោះតែម្តង។

បុរសអេសាវធ្លាក់ចូលក្នុងចំណាត់ថ្នាក់មនុស្សបែបនេះ។ គាត់មិនមានចិត្តចង់ធ្វើការអ្វីមួយដែលទាក់ទងខាងព្រលឹងវិញ្ញាណសោះឡើយ។ បើមាននរណាហៅគាត់ថាជាចាស់ទុំរបស់ក្រុមជំនុំ ឬក៏គ្រូគង្វាល គាត់យល់ថា អ្នកនោះឯងមើលងាយគាត់ខ្លាំងណាស់។ ភ័ស្តុតាងបង្ហាញច្បាស់ត្រង់នេះថា គាត់មិនចង់រក្សាសិទ្ធិជាបងច្បងនោះ ទេ។ បើសិនជាគំនិតអំពីដំណើរដែលថា អោយពូជពង្សរបស់គាត់ បានមានព្រះយេស៊ូវប្រសូតមកនោះ ជារឿងមួយដែលគាត់យល់ថា គេមើលងាយគាត់ជាទីបំផុត។ តាមពិតទៅ មិនមែនតែអេសាវម្នាក់ប៉ុណ្ណោះទេ មនុស្សណាក៏ដូចជាមនុស្សណាដែរ មិនចង់អោយព្រះយេស៊ូវកើតនៅក្នុងខ្សែស្រឡាយរបស់ខ្លួនឡើយ។

យ៉ាកុបឃើញឱកាសដ៏ល្អនេះ បានមកដល់គាត់ក៏និយាយថា "មានអីបង បើកាលណាបងលក់អំណាចបងច្បងមកអោយខ្ញុំ ខ្ញុំអោយសំឡទៅបងមួយចាន"។ អេសាវសប្បាយចិត្តណាស់ ជាមួយនឹងការដូរដោះបែបនេះ។ គាត់បាននិយាយតបទៅវិញថា "បងស្លាប់ឥឡូវហើយ ដូច្នេះ តើអំណាចនោះ មានប្រយោជន៍អ្វីដល់បងទៀត?" ត្រង់នេះ គាត់ចង់និយាយថា រវាងសិទ្ធិបងច្បង ហើយនិងសំឡមួយចាន បងសុខចិត្តអោយ

តម្លៃទៅសម្លរមួយចាននេះ ជាជាងអំណាចកូនច្បង។ អំណាចកូនច្បង សបញ្ជាក់អំពីតម្លៃផ្នែកខាងឯព្រលឹងវិញ្ញាណ។

ឯត្រង់កិរិយា ដែលយ៉ាកុបបោកប្រាស់បងខ្លួននេះ ក៏ខុសដែរ។ ព្រះជាម្ចាស់បានសន្យារួចហើយថា "កូនច្បងត្រូវបម្រើប្អូន"។ អំណាចមរតកបងច្បងនេះ នឹងធ្លាក់មកដល់យ៉ាកុបនៅថ្ងៃណាមួយជាមិនខាន តាមពេលវេលានិងផែនការរបស់ព្រះ។ ប៉ុន្តែយ៉ាកុបមិនរង់ចាំទេ គាត់សុខចិត្តក្តាប់យកសេចក្តីសន្យារបស់ព្រះមុនពេលកំណត់។ គាត់បានដណ្តើមយកអំណាចកូនច្បងដោយការបោកប្រាស់។ គាត់គួរតែរង់ចាំព្រះអង្គដើម្បីប្រទានមកអោយគាត់ល្អជាជាង។

លោកយ៉ាកុប ជាមនុស្សដែលធ្វើអ្វីអោយតែមានប្រយោជន៍សម្រាប់ខ្លួនផ្ទាល់។ លោកមិនរង់ចាំការដែលព្រះជាម្ចាស់ធ្វើអោយលោកនោះទេ។ គាត់គិតថាក្នុងនាមគាត់ជាអ្នករកស៊ីម្នាក់ គាត់ត្រូវកើបចំណេញអោយបានឆាប់អោយបានច្រើនជាទីបំផុត។ ដំបូងឡើយ គាត់ជាមនុស្សដែលលោកីយ៍អោយតម្លៃជាទីបំផុត។ ប៉ុន្តែព្រះជាម្ចាស់មិនអនុញ្ញាតអោយគាត់ធ្វើយ៉ាងដូច្នេះរហូតទេ បានជាព្រះអង្គបញ្ជូនគាត់អោយទៅរៀនសាលាគម្ពីរ ឯសាលាគម្ពីររបស់លោកនោះមានលោកឡាបាន់ជានាយកសាលាផង។ សាលាគម្ពីររបស់ឡាបាន់ ឈ្មោះសាលាគម្ពីរទល់ផ្លូក។ នៅសាលាគម្ពីរនោះលោកជាមនុស្សមានប្រាជ្ញា ឯឡាបាន់ក៏ជាមនុស្សឆ្លាតវ័យណាស់ដែរ។ ទោះបីយ៉ាកុបស្ថិតនៅក្រោមក្រសែភ្នែករបស់មនុស្សវៃឆ្លាតឈ្មោះឡាបាន់ យ៉ាកុបនៅតែបន្តដឹកនាំខ្សែជីវិតរបស់គាត់តាមបាវចនាថា "អ្វីដែលអញចង់បាន គឺត្រូវតែបាន"។

**យ៉ាកុបក៏និយាយថា ចូរស្បថឱ្យខ្ញុំឥឡូវចុះ រួចគាត់ក៏ស្បថឱ្យ ហើយលក់អំណាចនោះឱ្យដល់យ៉ាកុបទៅ យ៉ាកុបក៏ឱ្យនំបុ័ងនឹងសំឡសណ្តែកបាយដល់អេសាវ គាត់ក៏បរិភោគរួចក្រោកដើរចេញបាត់ទៅ អេសាវបានមើលងាយអំណាចមរដកនៃបងច្បងរបស់ខ្លួនដោយអាការយ៉ាងដូច្នោះ (លោកុ.២៥:៣៣-៣៤)។**

"អេសាវបានមើលងាយអំណាចមរដកនៃបងច្បងរបស់ខ្លួន"។ បន្ទាប់ពីបានដូរដោះវត្ថុទាំងពីរហើយ អេសាវអង្គុយទទួលទានសំឡយ៉ាងឆ្ងាញ់។ សិទ្ធិជាបងច្បងមិនមានន័យអ្វីសោះសម្រាប់រូបគាត់។ សិទ្ធិជាបងច្បង ដែលជានិមិត្តរូបនៃកិច្ចការខាងព្រលឹងវិញ្ញាណនេះ គ្មានតម្លៃអ្វីទេចំពោះអេសាវ។ សព្វថ្ងៃនេះ ខ្ញុំសង្កេតឃើញសមាជិករបស់ក្រុមជំនុំភាគច្រើន ច្រើនមានអត្តចរិកមិនប្រុងប្រយ័ត្នបែបដូចជាលោកអេសាវនេះដែរ។ សមាជិកក្រុមជំនុំភាគច្រើន គ្រាន់តែទៅព្រះវិហារអង្គុយស្តាប់ ហើយចេញពីព្រះវិហារមកវិញ ដោយមិនទាំងយល់ពីសេចក្តីអធិប្បាយដែលជាក្តីពិតខាងឯវិញ្ញាណ សម្រាប់អោយគេត្រូវរស់នៅនោះយ៉ាងដូចម្តេចផង។ ខ្ញុំជឿថា គ្រីស្ទបរស័ទពិតប្រាកដគឺជាគ្រីស្ទបរិស័ទដែល ព្រមចុះចូលនឹងព្រះវិញ្ញាណនៃព្រះដែលបង្ហាត់បង្រៀនគេ ព្រមទាំងដឹកនាំជីវិតគេគ្រប់ពេល គ្រប់វេលា និងគ្រប់វិស័យផងដែរ។ បើ

តាមខ្ញុំសង្កេតមើលមនុស្សសព្វថ្ងៃនេះ មានលក្ខណៈបែបដូចខ្ញុំអោយឧទាហរណ៍ខាងក្រោមនេះ។ ឧទាហរណ៍ថា នៅក្នុងគ្រួសារមួយមានព្រះគម្ពីរដែល ជីទួតរបស់ខ្លួន បានបន្សល់ទុកនៅក្នុងផ្ទះនោះ។ ដល់ពេលក្រោយមកទៀត ចៅទួតរបស់គាត់ធំឡើងឃើញព្រះគម្ពីរនោះមិនដែលមាននរណាយកដៃទៅប៉ះបន្តិចទេ។ មានអ្នកជិតខាងម្នាក់ឃើញព្រះគម្ពីរនោះដាក់នៅលើធ្នឹមផ្ទះ គាត់ក៏បបួលក្មេងនោះថា "លក់គម្ពីរនោះមកខ្ញុំអោយ៥០០៛"។ ក្មេងនោះក៏យកព្រះគម្ពីរនោះទៅអោយអ្នកជិតខាង ហើយបានប្រាប់ថា "ខ្ញុំចង់បោះចោលគម្ពីរនេះយូរហើយ ប៉ុន្តែវាគ្មានឱកាស ឥឡូវនេះ បាន៥០០៛ ខ្ញុំសុខចិត្តលក់ជូនអ៊ំក៏បាន!" អ្នកជិតខាងក៏និយាយមកវិញថា "ខ្ញុំមិនមែនទិញព្រះគម្ពីរនេះយកទៅអានទេ ខ្ញុំទិញព្រះគម្ពីរនេះទៅដុតចោល"។ ក្នុងរឿងលក់គម្ពីរចោល នេះ អេសាវបានធ្វើដូចក្មេងម្នាក់ខាងលើគឺ សុខចិត្តលក់សិទ្ធិបងច្បងរបស់ខ្លួនចោល។ ប៉ុន្តែយ៉ាកុបក៏ប្រព្រឹត្តខុសឆ្គងខ្លាំងណាស់ដែរ ដ្បិតគាត់ប្រើប្រាជ្ញាឆ្លាតវៃរបស់គាត់ ដើម្បីបោកប្រាស់អោយបានអ្វីដែលគាត់ចង់បាន។ យើងនឹងឃើញហេតុរណ៍នេះ រឹតតែច្បាស់លាស់ជាងនោះទៅទៀត នៅក្នុងជំពូក២៧នៃព្រះគម្ពីរលោកុប្បត្តិនេះ។ ទំរាំដល់យើងជួបគ្នាលើកក្រោយទៀត សូមព្រះជាម្ចាស់ប្រទានពរដល់លោកអ្នកកុំបីអាក់ខានឡើយ!